**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ..៧២..សសរ....

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីជំរុញការអភិវឌ្ឍផ្លូវដែកនៅកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីជំរុញការអភិវឌ្ឍផ្លូវដែកនៅកម្ពុជា ដែលមានសមាភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ប៉េង ពោធិ៍នា** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- | លោកជំទាវ **ភុយ សុជានី** | រដ្ឋលេខាធិការប្រចាំការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | ឯកឧត្តម **ឡាង វ៉ាន់** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៤- | ឯកឧត្តម **លុច្ស រចនា** | រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥- | ឯកឧត្តម **រស់ សីលវ៉ា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |



https://www.moj.gov.kh/kh/law-regular

| | | |
|---|---|---|
| ៦- ឯកឧត្តម **សៅ សុភាព** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- ឯកឧត្តម **លឹម ពុទ្ធិជាតិ** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ទ៉ាស៊ឹម សុរិយា** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩- ឯកឧត្តម **សំរ៉ែឌី ណារ៉ូ** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០- ឯកឧត្តម **សុន សុខភេទ** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១- ឯកឧត្តម **ប៉ែន ធីរុទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២- ឯកឧត្តម **សឹម យ៉ារ៉ែន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៣- ឯកឧត្តមបណ្ឌិត **លឹម អ៊ីង** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៤- ឯកឧត្តម **សួន ភារិទ្ធ** | អគ្គលេខាធិការរងនៃគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥- ឯកឧត្តម **ភែន រដ្ឋា** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៦- ឯកឧត្តម **សឿន ម៉ុនលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧- ឯកឧត្តម **ហេង រត្នពិសិដ្ឋ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសាធារណការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨- ឯកឧត្តម **ហ៊ាង ឧត្តរា** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៩- ឯកឧត្តម **ឈួន ច័ន្ទ** | អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២០- ឯកឧត្តម **ឈៀង ពេជ្រ** | អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារកម្ម ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២១- លោក **អ៊ុក អ៊ួក** | តំណាងនាយកដ្ឋានផ្លូវដែក ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២២- លោក **រ៉ាយ រុំ** | ប្រធានស្ដីទីនៃនាយកដ្ឋានផ្លូវដែក ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២៣- តំណាងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ | | សមាជិក។ |

**ប្រការ២ .-**

ក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីជំរុញការអភិវឌ្ឍផ្លូវដែកនៅកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្ដល់យោបល់អំពីនីតិវិធី ក្របខ័ណ្ឌគតិយុត្ត បច្ចេកទេស ប្រសិទ្ធភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ បរិស្ថាន សង្គម និងនយោបាយឱ្យបានច្បាស់លាស់ និងស៊ីជម្រៅគ្រប់ទិដ្ឋភាពលើការសិក្សា និងអភិវឌ្ឍផ្លូវដែកនៅកម្ពុជា
- សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយគណៈកម្មការជាតិអភិវឌ្ឍន៍ និងកែទម្រង់ និងនាយកដ្ឋានមូលធនបរទេស និងវិនិយោគក្រៅប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិនលើការសិក្សា និងរៀបចំផែនការអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា
- រៀបចំផែនការសកម្មភាពការងារ ដើម្បីជំរុញការសិក្សា និងរៀបចំផែនការមេអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា



https://www.moj.gov.kh/kh/law-regular

- សហការជាមួយអាជ្ញាធរដែនដី និងភាគីពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការសិក្សា ការអង្កេត និងការប្រមូលចងក្រងទិន្នន័យពាក់ព័ន្ធនឹងផ្លូវដែកនៅកម្ពុជា
- សម្របសម្រួល និងពិនិត្យលទ្ធភាពជ្រើសរើសក្រុមហ៊ុនជំនាញ ឬដៃគូអភិវឌ្ឍ ដើម្បីអនុវត្តការសិក្សា និងរៀបចំផែនការមេអភិវឌ្ឍន៍ផ្លូវដែកនៅកម្ពុជា
- ធ្វើរបាយការណ៍វឌ្ឍនភាពការងារជូនប្រមុខរាជរដ្ឋាភិបាលជ្រាប និង/ឬស្នើសុំការសម្រេច។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិកនៃក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងអនុវត្តភារកិច្ចតាមការប្រគល់របស់ប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួង។ ករណីអវត្តមាន ប្រធានត្រូវប្រគល់សិទ្ធិជូនអនុប្រធាន ១រូប ដឹកនាំកិច្ចប្រជុំជំនួស។

ប្រធានក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញតំណាងពីក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងអ្នកជំនាញដទៃទៀត ឱ្យចូលរួមប្រជុំ និងផ្តល់យោបល់ តាមការចាំបាច់។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**ប្រការ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ មករា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular